ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៣ ឆ្នាំ២០១៦
# វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ៖ កាលានុវត្តភាព និងហានិភ័យ

កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៣ ឆ្នាំ២០១៦ ស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ៖ កាលានុវត្តភាព និងហានិភ័យ" ក្រោមអធិបតីភាពរបស់លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា ។ គោលបំណងនៃសន្និសីទនេះគឺដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងពិភាក្សាទៅលើបញ្ហាចម្បងៗ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ។

អង្គសន្និសីទបានពិភាក្សាលើប្រធានបទចំនួន ៤ គឺ ៖ i/- បុគ្គលិកលក្ខណៈនៃការគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាៈ ប្រសិទ្ធភាព ប្រតិបត្តិការ និងគោលបំណងនៃការគ្រប់គ្រង ii/- ហានិភ័យនៃភាពខុសគ្នារវាងផលិតផលមីក្រូហិរញ្ញវត្ថុ និងតម្រូវការហិរញ្ញវត្ថុរបស់អតិថិជន iii/- កត្តាកំណត់ឥណទានមិនដំណើរការរបស់វិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា និង iv/- ការយល់ដឹងពីអត្រាការប្រាក់ ។ អ្នកចូលរួមក្នុងសន្និសីទនេះ រួមមាន តំណាងមកពីក្រសួងពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ សេដ្ឋវិទូ និស្សិត និងសាធារណៈជន ជាង ២៥០នាក់ ។

សន្និសីទបានប្រព្រឹត្តទៅដោយជោគជ័យនិងផ្លែផ្កា និងបានលើកឡើងនូវអនុសាសន៍សំខាន់ៗសម្រាប់ជូនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាជ្ញាធរ និងភាគីពាក់ព័ន្ធ ដើម្បីពិចារណាយកទៅបញ្ចូលក្នុងការអនុវត្ត និងរៀបចំគោលនយោបាយ សំដៅធានានិរន្តរភាពនៃការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ជាពិសេស រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

ដើម្បីបន្តលើកកម្ពស់ការស្រាវជ្រាវប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា គ្រោងនឹងរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចលើកទី៤ នៅឆ្នាំ២០១៧ ខាងមុខទៀត ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh